**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការ
ខេត្តសៀមរាប-ឧត្តរមានជ័យ
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ៥១២ ចុះថ្ងៃទី ៣១
ខែ សីហា ឆ្នាំ ២០០៥
<u>សាលក្រម</u>
លេខ ៥០ "យ" ចុះថ្ងៃទី ១៤
ខែ មិថុនា ឆ្នាំ ២០០៦

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប នាថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ចៅក្រមតុលាការខេត្តសៀមរាប

**<u>តំណាងអយ្យការ</u>**

លោក[redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តសៀមរាប

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក[redacted]

**<u>ដើម្បីជំនុំជំរះ</u> :**

សំណុំរឿងព្រហ្មទណ្ឌលេខ ៥១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

១-ឈ្មោះ **ឃ សរ** ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកណ្តៀង ឃុំកណ្តៀង ស្រុកកណ្តៀង ខេត្តពោធិសាត់ កំរិតវប្បធម៌ថ្នាក់ទី៩ចាស់ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិកណ្តៀង ឃុំកណ្តៀង ស្រុកកណ្តៀង ខេត្តពោធិសាត់ មុខរបរគ្មាន ប្រពន្ធឈ្មោះ **ម សធទ** មានកូន ០១នាក់ ឪពុកឈ្មោះ **ឃ ឃ** (រ) ម្តាយ ឈ្មោះ **ស ឃ** (រ) ទោសពីមុន *គ្មាន* ។

ចាប់ខ្លួនថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥ ។

ឃុំខ្លួនថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ ។

២-ឈ្មោះ **ជ ជ** ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូរ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កំរិតវប្បធម៌ថ្នាក់ទី៤ថ្មី សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិស្រង៉ែ ឃុំស្រង៉ែ ស្រុកសៀមរាប ខេត្តសៀមរាប មុខរបររត់ម៉ូតូឌុប ប្រពន្ធឈ្មោះ **ត ឃ** មានកូន ០៣នាក់ ឪពុកឈ្មោះ **ច ជ** (ស) ម្តាយឈ្មោះ **ម ម** (ស) ទោសពីមុនមាន ។

ចាប់ខ្លួនថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥

ឃុំខ្លួនថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥

សាលក្រមនេះត្រូវបានចូលជាស្ថាពរ ចាប់ពីថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ដោយគ្មានភាគីណាមួយប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។
សៀមរាប ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និង ត្រា [redacted]



Scanned with CamScanner

ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គ ឆ ភេទស្រី អាយុ ៥៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប មុខរបរមេផ្ទះ ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

ឈ្មោះ ឃ សរ ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៦ឆ្នាំ និង ឈ្មោះ ៩ ៩ ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៥ឆ្នាំ តាមសាលក្រមលេខ ០៩ "គ" ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

ឈ្មោះ ឃ សរ និង ឈ្មោះ ៩ ៩ បានបបួលគ្នាដើរយកទូរស័ព្ទ និង វិទ្យុទាក់ទងតាមផ្ទះ ដោយប្រើរូបភាពធ្វើជាអ្នកជួលផ្ទះ ។ កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ វេលាម៉ោង ៨:០០ព្រឹក ៩ ៩ បានបើកម៉ូតូឌុបនសេ ១២៥ ពណ៌ក្រហមស៊េរីឆ្នាំ ២០០៥ របស់វាឌុបឈ្មោះ ឃ សរ ទៅផ្ទះរបស់ឈ្មោះ គ ឆ ស្ថិតនៅបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ ពេលទៅដល់ ៩ ៩ និង ឃ សរ ក៏ប្រើល្បិចសួររកជួលផ្ទះអោយជនជាតិកូរ៉េ ហើយសុំនាង គ ឆ ចូលមើលផ្ទះ ហើយពួកវាសរសើរថា រៀបចំបានល្អ ។ ក្រោយមកឈ្មោះ ៩ ៩ ក៏សុំទឹកផឹក នាង គ ឆ ដើរទៅយកទឹកនៅឯផ្ទះបាយ ឆ្លៀតពេលនោះ ៩ ៩ បានយកទូរស័ព្ទដៃពណ៌ទឹកប៊ិចមួយគ្រឿង ម៉ាកណូគា៣៣១០ ដែលទុកនៅលើតុក្នុងបន្ទប់ទទួលភ្ញៀវដាក់ក្នុងហោប៉ៅខោខាងស្តាំ ។ ក្រោយពីផឹកទឹករួចជនទាំងពីរនាក់ក៏លានាង គ ឆ ទៅវិញ ។ បន្ទាប់មកនាង គ ឆ រកទូរស័ព្ទប្រើ តែរកមិនឃើញទើបមានការសង្ស័យថា ៩ ៩ និង ឈ្មោះ ឃ សរ យកទូរស័ព្ទខាងលើ ។ បន្ទាប់ពីបានទូរស័ព្ទហើយពួកគេក៏យកទៅលក់អោយជនមិនស្គាល់ឈ្មោះបានតម្លៃ ២០$ "ម្ភៃដុល្លា"ហើយពួកវាទាំងពីរនាក់ចែកប្រាក់គ្នាម្នាក់ពាក់កណ្តាល ។ ឈ្មោះ ឃ សរ និង ៩ ៩ ត្រូវសមត្ថកិច្ចចាប់ខ្លួននៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥ ក្នុងសំណុំរឿងមួយផ្សេងទៀត ហើយបានផ្តន្ទាទោសតាមអំណាចសាលក្រមដូចខាងលើ ។

ម៉ូតូឌុបនសេ ១២៥ ពណ៌ក្រហម ស៊េរី ២០០៥ មួយគ្រឿងលេខតួ និង លេខម៉ាស៊ីន ៨០៨៤៩៥០៧ ត្រូវដកហូតទុកជាសម្បត្តិរដ្ឋ តាមសាលក្រមលេខ ០៩"គ" ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

ក្នុងរឿងនេះនាង គ ឆ ជាជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងជាប្រាក់ចំនួន ១០០ ដុល្លា "មួយរយដុល្លាសហរដ្ឋ" ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ឃ សរ បានឆ្លើយថា ខ្លួនសូមសារភាពថា ខ្លួនពិតជាអ្នកផ្តើមគំនិតក្នុងរឿងធ្វើស៊ីទូរស័ព្ទតាមផ្ទះ ។ បក្សពួករបស់ខ្លួនមានឈ្មោះ ៩ ៩ ធ្វើសកម្មភាពរួមគ្នាដោយខ្លួន និង ឈ្មោះ ៩ ៩ ប្រើរូបភាពជាអ្នកជួលផ្ទះអោយជនជាតិកូរ៉េ ដោយខ្លួន និង ឈ្មោះ ៩ ៩ ធ្វើជាអង្គរក្សឯកឧត្តម អ៊ុខ អឿន កុហក់គេ តែតាមការពិតខ្លួនគ្មានធ្វើអ្វីទេ ។ ខ្លួន និង ឈ្មោះ ៩ ៩ ធ្វើសកម្មភាពយកទូរស័ព្ទគេបានសរុបចំនួន ១៨គ្រឿង "ដប់ប្រាំបីគ្រឿង" ជាច្រើនផ្ទះមិនចាំទេ ព្រោះច្រើនពេក ។ ខ្លួនសូមសារភាពថា ខ្លួនពិតជាបានយកទូរស័ព្ទដៃលើតុរបស់គេនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ដោយខ្លួន និង ឈ្មោះ ៩ ៩ ជាអ្នករកផ្ទះជួល



Scanned with CamScanner

ពេលនោះឈ្មោះ ៩ ៩ សុំទឹកផឹកម្ចាស់ផ្ទះទៅយកទឹកមកអោយខ្លួនផឹក ខ្លួនក៏ទៅដែរ ពេលនោះឈ្មោះ ៩ ៩ ក៏យកទូរស័ព្ទដៃដែលនៅលើតុ កន្លែងទទួលភ្ញៀវដាក់ចូលក្នុងហោប៉ៅខោ ក្រោយពីផឹកទឹករួចក៏នាំគ្នាចេញវិញ ។ ខ្លួន និង ឈ្មោះ ៩ ៩ យកទូរស័ព្ទទៅលក់អោយមនុស្សមិនស្គាល់ឈ្មោះបានតម្លៃ ២០$ "ម្ភៃដុល្លា" ចែកគ្នាម្នាក់ពាក់កណ្ដាល ។

ជនជាប់ចោទឈ្មោះ ៩ ៩ បានឆ្លើយថា ខ្លួនសូមសារភាពថា ខ្លួនពិតជាបានយកទូរស័ព្ទដៃម៉ាកណូគាគេនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ពិតប្រាកដមែន ដោយខ្លួន និង ឈ្មោះ ម ស ប្រើរូបភាពធ្វើជាសួរជួលផ្ទះរបស់គេ ។ ពេលខ្លួន និង ឈ្មោះ ម ស ចូលទៅសួររកជួលផ្ទះ ខ្លួនធ្វើជាសុំទឹកផឹក ឆ្លៀតពេលដែលម្ចាស់ផ្ទះគេយកទឹកមកអោយខ្លួន ខ្លួនក៏យកទូរស័ព្ទដែលម្ចាស់គេទុកលើតុក្នុងបន្ទប់ទទួលភ្ញៀវច្រកក្នុងហោប៉ៅខោ បន្ទាប់ពីផឹកទឹកហើយក៏នាំគ្នាចេញមកក្រៅ ម្ចាស់គេមិនដឹងថា ខ្លួនយកទូរស័ព្ទគេទេ ខ្លួន និង ឈ្មោះ ម ស បានយកម៉ូតូរ៉ូឡានោះទៅលក់ មនុស្សមិនស្គាល់ឈ្មោះបានតម្លៃ ២០$ "ម្ភៃដុល្លាសហរដ្ឋអាមេរិក" ចែកគ្នាម្នាក់ពាក់កណ្ដាល ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ គ ឆ បានឆ្លើយថា កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ វេលាម៉ោង ៨:០០ព្រឹក ស្រាប់តែមានមនុស្សប្រុសចំនួន ០២នាក់ បានចូលមកសុំជួលផ្ទះខ្លួនអោយកូរ៉េ ពួកវាជិះម៉ូតូឌុនសេ ១២៥ ពណ៌ក្រហមចូលមក ។ ក្រោយមកចោរនោះក៏បានសុំមើលផ្ទះ ពួកវាសរសើរថា ស្អាតបន្ទាប់មកវាក៏សុំទឹកផឹក ខ្លួនបានទៅយកទឹកនៅឯក្រោយផ្ទះ ចំណែកពួកវានៅចាំឯបន្ទប់ទទួលភ្ញៀវ ក្រោយពីផឹកទឹករួចបានលាចេញទៅមានម្នាក់ដើរថយក្រោយ ។ រយៈពេលប្រហែល ១០នាទី ក្រោយមកកូនរបស់ខ្លួនបានរកទូរស័ព្ទ ដែលដាក់លើតុក្នុងបន្ទប់ទទួលភ្ញៀវបាត់មិនឃើញ ទើបខ្លួនសន្និដ្ឋានថាចោរទាំងពីរនាក់ ដែលមកជួលផ្ទះខ្លួននោះយកចេញទៅ ។ ក្នុងចំណោមចោរទាំង ០២នាក់នោះមានម្នាក់កំបុតជើងម្ខាង ។ ទូរស័ព្ទរបស់ខ្លួនម៉ាកណូគា ៣៣១០ពណ៌ទឹកប៊ិច កាលទិញតម្លៃ ១០០ដុល្លា សហរដ្ឋអាមេរិក ។

ក្នុងរឿងនេះ ខ្លួនជាជនរងគ្រោះ និង ជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងជម្ងឺចិត្ត ១០០ដុល្លា "មួយរយដុល្លាសហរដ្ឋ" ។ ចំពោះជនល្មើសសូមផ្ដន្ទាទោសតាមច្បាប់ចុះ ។

## តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានទោសថា

ជនជាប់ចោទបានសារភាពអស់មកហើយ ពុំខុសអ្វីពីដីកាសន្និដ្ឋានស្ថាពរទេ ។ តាងនាមខ្ញុំជាតំណាងអយ្យការសូមតម្កល់បទចោទប្រកាន់ដដែល ។ សង្ឃឹមថា លោកចៅក្រមនឹងចេញសាលក្រមផ្ដន្ទាទោសជនជាប់ចោទប្រកបដោយគតិបណ្ឌិត ។ ជនជាប់ចោទបាននិយាយសំដីជាចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនដោយក្ដីអនុគ្រោះ ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់ជនជាប់ចោទនិយាយសំដីចុងក្រោយបង្អស់

## តុលាការ

ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ វេលាម៉ោង ៨:០០នាទីព្រឹក ឈ្មោះ ម ស



Scanned with CamScanner

និង **ខ ខ** ប្រើល្បិចធ្វើជាដើររកជួលផ្ទះឱ្យជនជាតិកូរ៉េ សុំទឹកម្ចាស់ផ្ទះផឹក នាង គ ឆ ទៅយកទឹកមក អោយ **ខ ខ** មានឱកាសបានយកទូរស័ព្ទដៃម៉ាកណូគា៣៣១០ ពណ៌ទឹកប៊ិចមួយគ្រឿង ជាកម្មសិទ្ធិ របស់ឈ្មោះ គ ឆ នៅបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប យកទៅលក់បានតម្លៃ ២០ដុល្លា ចែកគ្នាម្នាក់ពាក់កណ្ដាល ដោយមានឈ្មោះ **ហ សរ** ជាអ្នកផ្ដើមគំនិត ហើយត្រូវសមត្ថកិច្ច ចាប់ខ្លួន ។

-យល់ឃើញថា អំពើប្រព្រឹត្តរបស់ឈ្មោះ **ហ សរ** និង **ខ ខ** មានចែង និង ផ្ដន្ទាទោសតាមមាត្រា ៦ នៃ ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

-ប៉ុន្តែបើពិនិត្យអោយបានដិតដល់ទៅឃើញថា ជនជាប់ចោទជាមនុស្សខ្វះការពិចារណា ជីវភាពក្រលំបាក ប្រព្រឹត្តបទល្មើសម្ដងហើយម្ដងទៀតមិនព្រមឈប់ ។

-យល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ គ ឆ ប្ដឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១០០ដុល្លា "មួយរយដុល្លាសហរដ្ឋអាមេរិក" តុលាការគប្បីពិចារណាដល់បញ្ហានេះ ។

## <u>ហេតុដូច្នេះទើបសម្រេច</u>

១-ផ្ដន្ទាទោស :

ក-ឈ្មោះ **ហ សរ** ដាក់គុកកំណត់ ០៥ឆ្នាំ "ប្រាំឆ្នាំ " គិតបន្តពីថ្ងៃផុតកំណត់ទទួលរងទោសតាម អំណាចសាលក្រមលេខ ០៩ "គ" ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

ខ-ឈ្មោះ **ខ ខ** ដាក់គុកកំណត់ ០៥ឆ្នាំ "ប្រាំឆ្នាំ" គិតបន្តពីថ្ងៃផុតកំណត់ទទួលរងទោសតាមអំណាច សាលក្រមលេខ ៩"គ" ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ តាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

២-បង្គាប់អោយឈ្មោះ **ហ សរ** និង ឈ្មោះ **ខ ខ** រូបរួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ២០០.០០០ រៀល "ម្ភៃម៉ឺនរៀល" ទៅឈ្មោះ គ ឆ ជាដើមបណ្ដឹងរដ្ឋប្បវេណី ។ សុំលើសពីនេះលើកចោល ។

ក្នុងករណីគ្មានប្រាក់សងធនទណ្ឌនេះទេ ត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា ៧ នៃច្បាប់ស្ដីពីការដាក់គុក បង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌគឺ ០២ឆ្នាំ ។

៣-សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ពេល ០២ខែ គិតពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា**
[redacted]

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**
[redacted]

**បានឃើញ**
*សៀមរាប,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
**ប្រធានតុលាការខេត្ត**
[redacted]

Scanned with CamScanner